# កាត StarCard

ក្រុមហ៊ុន ឈេហ្វ៍រ៉ន ( ខេមបូឌា ) លីមីតធីតក្នុងភាពជាដៃគូជាមួយ ធនាគារ កាណាឌីយ៉ា សូមណែនាំមកជូន ជាមួយប័ណ្ណ StarCard ។ ប្រព័ន្ធនៃការប្រើប្រាស់ប័ណ្ណនេះត្រូវបានបង្កើតឡើង ក្នុងគោលបំណង ផ្តល់ដល់អ្នកនូវការទូទាត់ចំណាយ ប្រកបដោយភាពរលូន និងងាយស្រួលបំផុត គ្រប់ពេលវេលាដែលអ្នកត្រូវការ។

StarCard ផ្តល់នូវភាពងាយស្រួល និងមានប្រសិទ្ធិភាពខ្ពស់បំផុត សំរាប់គ្រប់គ្រងការចំណាយ លើមធ្យោបាយដឹកជញ្ជូនរបស់អ្នក ដោយសារវាអាចបំរើក្នុងលក្ខណ:ជាប័ណ្ណចាក់ប្រេងឥន្ធន:កាល់តិច ដែលអនុញ្ញាតិអោយអ្នកជាវប្រេងឥន្ធន:កាល់តិចដែលមានគុណភាពខ្ពស់ ផ្តល់ថាមពលលាងសម្អាត Techron® នៅតាមបណ្តាស្ថានីយប្រេងឥន្ធន:កាល់តិចដែលអ្នកចូលចិត្ត ដោយមិនចាំបាច់ប្រើសាច់ប្រាក់សុទ្ធ។ រាល់ការជាវរបស់លោកអ្នក នឹងត្រូវបានកាត់ចេញពីគណនីក្នុងធនាគាររបស់អ្នកដោយស្វ័យប្រវត្តិ ដែលធ្វើអោយការទូទាត់របស់អ្នកគ្មានភាពសាំញ៉ាំ និងងាយស្រួល។

## សិទ្ធិក្នុងការទទួលយកប័ណ្ណ

រាល់អតិថិជនរបស់កាល់តិច និងធនាគារ កាណាឌីយ៉ា ដែលមានទឹកប្រាក់យ៉ាងតិច ៥០ដុល្លាសហរដ្ឋអាមេរិក តំកល់ក្នុងគណីសន្សំ គណនីចរន្ត ឬគណនី Overdraff សុទ្ធតែមានសិទ្ធិស្នើសុំប័ណ្ណ StarCard នេះបាន ទាំងអស់។

## ទទួលស្គាល់យ៉ាងទូលំទូលាយ

StarCard ត្រូវបានទទួលស្គាល់នៅគ្រប់ស្ថានីយប្រេងឥន្ធន:កាល់តិច ដែលមានទីតាំងនៅភ្នំពេញ និង ខេត្តសៀមរាប។



## អត្ថប្រយោជន៍

- ទទួលស្គាល់នៅគ្រប់បណ្តាស្ថានីយប្រេងឥន្ធនៈកាល់តិច
- មិនចាំបាច់មានសាច់ប្រាក់ មិនចាំបាច់ប្រើ Petty Cash និង មិនចាំបាច់ប្រើវិក័យប័ត្រ
- បន្ថែមនូវលេខកូដសម្ងាត់ ដើម្បីទប់ស្កាត់ការក្លែងបន្លំ និងរំលោភលើការប្រើប្រាស់ដែលអាចកើតមានឡើង
- ទទួលបានរបាយការណ៍លំអិតស្តីពីការចំណាយ ក្នុងគណនី
- មិនគិតថ្លៃសេវាប្រចាំឆ្នាំ

## របៀបស្នើសុំធ្វើប័ណ្ណ StarCard

- បំពេញទំរង់បែបបទស្នើសុំប័ណ្ណ StarCard ដែលអាចរកបាននៅតាមបណ្តាស្ថានីយប្រេងឥន្ធនៈ កាល់តិច ឬសាខាធនាគារ កាណាឌីយ៉ា រួចដាក់ពាក្យស្នើសុំនេះនៅសាខាណាមួយ នៃធនាគារ កាណាឌីយ៉ា ។
- តម្កល់សាច់ប្រាក់ក្នុងចំនួនយ៉ាងតិច ៥០ដុល្លា នៅក្នុងគណនីសន្សំ គណនីចរន្ត ឬគណនី Overdraff ។

## ដំណើការនៃការធ្វើប័ណ្ណមានរយៈពេល ៣ ថ្ងៃ

- ពេលធនាគារអនុម័តយល់ព្រមអោយចេញប័ណ្ណភ្លាម អ្នកតំណាងផ្នែកសេវាកម្មអតិថិជននឹង ធ្វើការទំនាក់ទំនង និងផ្តល់ជូននូវប័ណ្ណ StarCard ជាមួយនឹងលេខកូដសំងាត់ ដែលអាចអោយអ្នកចូលទៅកាន់គណនីរបស់អ្នកបាន តាមរយៈម៉ាស៊ីន ATM។